# ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១៤០១

## ស្តីពី

## ការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
នា-រដ្ឋបាល និង បុគ្គលិក
ចូល
លេខ 667
ថ្ងៃទី 29 ខែ 12 ឆ្នាំ 2009
បញ្ជូន

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពុហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់អនុសញ្ញាស្តីពីសិទ្ធិកុមារដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់ បានចុះហត្ថលេខានៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩២ និងបានផ្តល់សច្ចាប័ននៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៩

ROYAUME DU CAMBODGE • LE MINISTERE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

# ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១._**

ត្រូវបានបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដែលសរសេរអក្សរកាត់ថា **ក.ជ.ក.** ដើម្បីជាយន្តការសម្របសម្រួល និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាល លើការងារទាក់ទងនឹងការរស់រានមានជីវិត ការអភិវឌ្ឍ ការការពារ ការលើកកម្ពស់សុខុមាលភាព និងការចូលរួមចំណែករបស់កុមារ ។

## ជំពូកទី២

## សមាសភាព

**មាត្រា២._**

**ក.ជ.ក.** មានសមាសភាពដូចតទៅ ៖

| | | |
|---|---|---|
| - សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី | | ប្រធានកិត្តិយស |
| - រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងកិច្ចការនារី | ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល | ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១រូប | អនុប្រធាន |
| - អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងការពារជាតិ | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងផែនការ | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ១រូប | សមាជិក |

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

| | | |
|---|---|---|
| - អនុរដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្មរ៉ែនិងថាមពល | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា | ១រូប | សមាជិក |
| - តំណាងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | ១រូប | សមាជិក |
| - តំណាងសមាគមជាតិកាកបាទក្រហមកម្ពុជា | ១រូប | សមាជិក |
| - តំណាងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី | ១រូប | សមាជិក |
| - តំណាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន | ១រូប | សមាជិក |
| - អគ្គលេខាធិការ **ក.ជ.ក.** | | សមាជិកអចិន្ត្រៃយ៍។ |

សមាសភាពជាក់ស្តែងរបស់ **ក.ជ.ក.** ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៣
## តួនាទីនិងភារកិច្ច

**មាត្រា៣.-**

**ក.ជ.ក.** មានតួនាទីនិងភារកិច្ចដូចតទៅ ៖

- ពិគ្រោះយោបល់ សម្របសម្រួលសកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងបញ្ហាកុមារ
- ពិនិត្យ តាមដាន វាយតម្លៃ លើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ កម្មវិធីជាតិសម្រាប់កុមារនៅកម្ពុជា និងលើកសំណើជូនរាជរដ្ឋាភិបាលអំពីតម្រូវការ និងបញ្ហាទាំងឡាយដែលធានាឧត្តមប្រយោជន៍របស់កុមារ
- ចូលរួមពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងកុមារ និងផ្តល់អនុសាសន៍ស្របនឹងអនុសញ្ញា និងបទដ្ឋានអន្តរជាតិផ្សេងៗស្តីពីកុមារ
- ធ្វើការផ្សព្វផ្សាយច្បាប់ អនុសញ្ញាស្តីពីសិទ្ធិកុមារ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានា របស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងបញ្ហានានារបស់កុមារ និងបំផុសចលនាគាំទ្រការអនុវត្តសិទ្ធិកុមារឱ្យមានប្រសិទ្ធភាព
- រៀបចំគោលនយោបាយ ផែនការ កម្មវិធី និងសកម្មភាពផ្សេងៗ ដើម្បីឧត្តមប្រយោជន៍ដល់កុមារ មានជាអាទិ៍ ការគោរពនិងការអនុវត្តសិទ្ធិកុមារ ការរស់រានមានជីវិត ការអភិវឌ្ឍ ការការពារ ការលើកកម្ពស់សុខុមាលភាព ការចូលរួមចំណែករបស់កុមារ ការប្រឆាំងនឹងអំពើហិង្សា ការទប់ស្កាត់ ការលុបបំបាត់ការកេងប្រវ័ញ្ចគ្រប់រូបភាពមកលើកុមារ និងការប្រឆាំងនឹងការជួញដូរគ្រឿងញៀន

- ធ្វើទំនាក់ទំនងជាមួយសហគមន៍ជាតិ អន្តរជាតិ ដែលមានការងារប្រហាក់ប្រហែលគ្នា ដើម្បីរកជំនួយឧបត្ថម្ភ និងផ្លាស់ប្តូរព័ត៌មាន និងបទពិសោធ និងទស្សនៈរីកចម្រើន ដែលទាក់ទងនឹងគោលដៅរួម ក្នុងការកែលម្អស្ថានភាពកុមារ
- ស្រាវជ្រាវ និងជូនព័ត៌មានស្តីពីសេចក្តីត្រូវការនិងបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងកុមារកម្ពុជា ជូនរាជរដ្ឋាភិបាល ស្ថាប័ន និងអង្គការនានាដែលមានសមត្ថកិច្ច
- ពិនិត្យ និងសម្រេចបទបញ្ជាផ្ទៃក្នុងរបស់ **ក.ជ.ក.**
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាអន្តរជាតិ ដែលពាក់ព័ន្ធនឹងសិទ្ធិរបស់កុមារ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន ។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ ក.ជ.ក.

**មាត្រា៤.-**

**ក.ជ.ក.** ត្រូវជួបប្រជុំយ៉ាងតិច ២ (ពីរ)ដងក្នុងមួយឆ្នាំ។ ក្នុងករណីចាំបាច់ **ក.ជ.ក.** អាចប្រជុំជាវិសាមញ្ញបាន តាមការអញ្ជើញរបស់ប្រធាន ។

ក្នុងមួយឆ្នាំម្តង **ក.ជ.ក.** ត្រូវធ្វើការបូកសរុបរបាយការណ៍ អំពីលទ្ធផលនៃការអនុវត្តកម្មវិធីការងារ និងអនុសាសន៍ដែល **ក.ជ.ក.** ត្រូវដាក់ជូនរាជរដ្ឋាភិបាល ។

**មាត្រា៥.-**

**ក.ជ.ក.** មានសិទ្ធិទាក់ទងនិងអញ្ជើញក្រសួង ស្ថាប័នពាក់ព័ន្ធនានា តំណាងកុមារ អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍ ដែលពុំមានចែងក្នុងមាត្រា២ នៃព្រះរាជក្រឹត្យនេះ ដើម្បីចូលរួមប្រជុំផ្តល់យោបល់ ឬធ្វើជាអ្នកសង្កេតការណ៍ ។

**មាត្រា៦.-**

របៀបរបបនៃការប្រជុំរបស់ **ក.ជ.ក.** ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ **ក.ជ.ក.** ។

**មាត្រា៧.-**

**ក.ជ.ក.** មានសិទ្ធិប្រើប្រាស់ត្រាដោយឡែករបស់ខ្លួន ដើម្បីបំពេញការងារ ។

**មាត្រា៨.-**

**ក.ជ.ក.** មានអគ្គលេខាធិការដ្ឋានមួយជាអង្គភាពប្រតិបត្តិ ដែលមានទីតាំងនៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា៩._**

អគ្គលេខាធិការដ្ឋាន **ក.ជ.ក.** ដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួនដែលតែងតាំងដោយព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន **ក.ជ.ក.** ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា១០._**

**ក.ជ.ក.** អាចបង្កើតគណៈកម្មការឬអនុគណៈកម្មការជំនាញមួយចំនួនតាមការចាំបាច់ ដែលសមាសភាពដឹកនាំរបស់គណៈកម្មការឬអនុគណៈកម្មការនីមួយៗ ត្រូវជ្រើសរើសពីសមាជិកនៃ **ក.ជ.ក.** និងដែលមានមន្ត្រីជំនាញ របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ តំណាងកុមារ អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍចូលរួមជាសមាជិក ។

សមាសភាព តួនាទី និងភារកិច្ចរបស់គណៈកម្មការឬអនុគណៈកម្មការជំនាញ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **ក.ជ.ក.** ។

**មាត្រា១១._**

**ក.ជ.ក.** អាចទទួលយកទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិឬអ្នកជំនាញការអន្តរជាតិមួយចំនួនតាមការចាំបាច់ ដើម្បីជួយការងារ **ក.ជ.ក.** និងអគ្គលេខាធិការដ្ឋាន ។

**មាត្រា១២._**

**ក.ជ.ក.** ត្រូវបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ថ្នាក់រាជធានី ខេត្ត និងបង្កើតក្រុមការងារដើម្បីកុមារនៅតាមក្រសួង ស្ថាប័ននីមួយៗ ។

សមាសភាព តួនាទី ភារកិច្ច និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ថ្នាក់រាជធានី ខេត្ត និងក្រុមការងារដើម្បីកុមារ នៅតាមក្រសួង ស្ថាប័ន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **ក.ជ.ក.** ។

## ជំពូកទី៥

## ប្រភពធនធាន

**មាត្រា១៣._**

**ក.ជ.ក.** មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

**ក.ជ.ក.** មានសិទ្ធិទទួលនិងគ្រប់គ្រងមូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ និងពីប្រភពផ្សេងៗទៀត សម្រាប់បំពេញការងាររបស់ខ្លួន ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា១៤.-**

អនុក្រឹត្យលេខ៥៦ អនក្រ.បក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៥.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត.០៩១២.១២២៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ : ១១០៧ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ ធ្នូ ឆ្នាំ២០០៩

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# អង្គការលេខ
# របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ




ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *